**សេចក្តីថ្លែងការណ៍នៅចុងបញ្ចប់បេសកកម្ម**

<u>សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ</u>
<u>ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា</u>
<u>សាស្ត្រាចារ្យ រ៉ូណា ស្មីត</u>
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦

**ពិនិត្យមុននឹងផ្ញើចេញ**

ខ្ញុំមានកិត្តិយសនិងមានសេចក្តីរីករាយដែលបានបំពេញបេសកកម្មលើកទីពីររបស់ខ្ញុំនៅព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីខ្ញុំទទួលបានការតែងតាំងពីក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ក្នុងខែមីនា ឆ្នាំ២០១៥ ជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជាចំពោះការអញ្ជើញនិងកិច្ចសហប្រតិបត្តិការ ដែលបានផ្តល់នៅមុនពេល និងនៅក្នុងពេលបំពេញបេសកកម្មនេះ។

ខ្ញុំបានមានឯកសិទ្ធិជួបប្រជុំជាមួយមន្ត្រីជាន់ខ្ពស់នានាដែលមានសន្តានចិត្តចំណាយពេលវេលា និងចែករំលែកចំណេះដឹងផ្ទាល់ខ្លួន ក្នុងនោះរួមមាន៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា ឯកឧត្តម ងួន ញ៉ិល ប្រធានស្តីទីនៃរដ្ឋសភា សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម អេង ឆៃអ៊ាង ប្រធានគណៈកម្មការទី១ នៃរដ្ឋសភា ទទួលបន្ទុកសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត ឯកឧត្តម គង់ គាំ ប្រធានគណៈកម្មការទី១ នៃព្រឹទ្ធសភា ទទួលបន្ទុកសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត ឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឯកឧត្តម អង្គ វង្ស វឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តម ជា សុផារ៉ា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តម ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការក្រសួងកិច្ចការនារី ឯកឧត្តម ស៊ិក ប៊ុនហុក ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងឯកឧត្តម ម៉ក់ សម្បត្តិ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

ខ្ញុំបានជួបផងដែរ ជាមួយសមាជិកនៃប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជា សហគមន៍អ្នកការទូត និងតំណាងផ្សេងៗនៃតួអង្គសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត។ ខ្ញុំបានធ្វើទស្សនកិច្ចទៅកាន់ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ ដែលនៅទីនោះ ខ្ញុំបានជួបប្រជុំជាមួយអាជ្ញាធរខេត្ត តំណាងសង្គមស៊ី

វិលនៅមូលដ្ឋាន សមាជិកសហគមន៍ជនជាតិដើមភាគតិច និងប្រជាជនក្នុងស្រុក និងតួអង្គវិស័យឯកជននានា។

នៅក្នុងជំនួបប្រជុំជាមួយក្រសួងផ្សេងៗនិងភាគីពាក់ព័ន្ធដទៃទៀត ខ្ញុំត្រូវបានប្រាប់ឲ្យដឹងពីកិច្ចខិតខំប្រឹងប្រែងសំដៅពង្រឹងស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស។ ជាពិសេស ខ្ញុំបានដឹងច្រើនថែមទៀតអំពីកិច្ចខិតខំប្រឹងប្រែងដែលបាននិងកំពុងធ្វើ ដើម្បីពង្រឹងការប្រព្រឹត្តទៅនៃប្រព័ន្ធតុលាការ ការអភិរក្សទាំងវប្បធម៌ខ្មែរនិងវប្បធម៌ជនជាតិដើមភាគតិច ការការពារឧទ្យានជាតិ និងការដោះស្រាយបញ្ហាដីធ្លី។ ខ្ញុំកត់សំគាល់ផងដែរ អំពីការចុះបញ្ជីអ្នកសុំសិទ្ធិជ្រកកោន ម៉ុងតាញ៉ាមកពីប្រទេសវៀតណាម ដែលជាជំហានវិជ្ជមានមួយឆ្ពោះទៅរកការកំណត់ និងការទទួលស្គាល់ឋានៈជនភៀសខ្លួនរបស់ពួកគេ។ ខ្ញុំស្វាគមន៍ផងដែរ នូវសមិទ្ធិផលសម្រេចបាននៃភាពស្មើគ្នាខាងយេឌ័រក្នុងការចុះឈ្មោះសិស្សចូលរៀន និងអត្រានៃអ្នកដែលបានបញ្ចប់កម្រិតបឋមសិក្សា។ ក្រសួងជាច្រើន បានរាយការណ៍ថា ខ្លួនបាននិងកំពុងចូលរួមអនុវត្តរបៀបវារៈកំណែទម្រង់ បើទោះជាដំណើរការទាំងនេះភាគច្រើននៅមិនទាន់បានបញ្ចប់ក្តី។ ខ្ញុំបានដឹងជាទូទៅអំពីការយល់ដឹង ដែលបាននិងកំពុងកើនឡើងអំពីសេចក្តីត្រូវការឲ្យមានការដោះស្រាយបញ្ហាប្រឈមខាងសិទ្ធិមនុស្ស។ ការណ៍នេះ មានលក្ខណៈផ្ទុយទៅនឹងស្ថានភាពនយោបាយកាន់តែធ្លាក់ដុនដាបឡើង ដែលខ្ញុំនឹងលើកនៅផ្នែកបន្ទាប់ក្នុងសេចក្តីថ្លែងការណ៍នេះ។

ដូចលោកអ្នកបានជ្រាបហើយ ក្នុងតួនាទីរបស់ខ្ញុំជាអ្នករាយការណ៍ពិសេស ខ្ញុំស្ថិតនៅឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយខ្ញុំបំរើការក្នុងសមត្ថភាពរបស់បុគ្គលខ្ញុំផ្ទាល់។ អាណត្តិរបស់ខ្ញុំមានតួនាទីមួយដែលមានមុខងារបីគឺ ផ្តល់ប្រឹក្សាយោបល់ តាមឃ្លាំមើល និងធ្វើរបាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ខ្ញុំជឿថា មុខងារទាំងបីនេះ គឺមានសារៈសំខាន់ដូចគ្នា និងជាប់ពាក់ព័ន្ធគ្នា។

គោលបំណងសំខាន់នៃបេសកកម្មនេះមានពីរគឺ លើកបញ្ហាផ្សេងៗនិងប្រមូលព័ត៌មានពិតសម្រាប់របាយការណ៍របស់ខ្ញុំដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅខែកញ្ញា បន្ថែមដោយព័ត៌មានដែលទទួលបានពីរាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធផ្សេងៗទៀត និងដើម្បីពិនិត្យមើលប្រធានបទស្តីពីសមភាព និងភាពមិនរើសអើង ដោយចាប់ផ្តើមពីការផ្តោតសំខាន់លើស្ត្រី និងជនជាតិដើមភាគតិច។ បេសកកម្មនេះ បានឲ្យខ្ញុំកាន់តែយល់ដឹងស៊ីជម្រៅថែមទៀតអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងទុក្ខលំបាករបស់ជនងាយរងគ្រោះ និងក្រុមបាត់បង់ឱកាសក្នុងសង្គម។

ការរើសអើង ទោះជាដោយមូលហេតុអ្វីក៏ដោយ ក៏នៅតែជាកង្វល់ស្របច្បាប់មួយ ខណៈពេលលើកកម្ពស់សិទ្ធិមនុស្សក្នុងសង្គមដែលមានសមភាពត្រឹមត្រូវ។ ការរើសអើងនេះ អាចត្រូវបានគេប្រើដើម្បីកម្រិតកំណត់ការទទួលបានសិទ្ធិមនុស្សដោយបុគ្គលនិងក្រុមផ្សេងៗក្នុងសង្គម។ ច្បាប់អន្តរជាតិចែងច្បាស់ថា សិទ្ធិសេរីភាព ត្រូវតែទទួលបានដោយគ្មានការប្រកាន់បែងចែកណាមួយឡើយ រួមទាំងហេតុផល ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ទំនោរផ្លូវភេទ ពិការភាព ឬស្ថានភាពដទៃផ្សេងទៀត។ រាជរដ្ឋាភិបា

លកម្ពុជា បានយល់ព្រមដោយស្ម័គ្រចិត្តចង់ភ្ជាប់កាតព្វអនុវត្តសន្ធិសញ្ញាអន្តរជាតិជាច្រើន ដែលចែងអំពីបទដ្ឋានទាំងនេះ។ ខ្ញុំបានជ្រើសរើសយកប្រធានបទទាំងនេះ ដើម្បីរកឲ្យឃើញភាពជាប់ជំពាក់ជាក់លាក់មួយចំនួននៃការរើសអើងសម្រាប់កម្ពុជា ហើយគ្រោងបន្តផ្តោតលើភាពងាយរងគ្រោះរបស់ក្រុមជាក់លាក់ទាំងនេះនៅក្នុងដំណើរបេសកកម្មរបស់ខ្ញុំនៅថ្ងៃខាងមុខ។

## ១.សិទ្ធិស្ត្រី

មួយក្នុងចំណោមកង្វល់ខ្លាំងរបស់ខ្ញុំគឺអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី ដែលបន្តបង្ហាញខ្លួន ជាការរំលោភសិទ្ធិមនុស្សទូទៅនៅកម្ពុជា តម្រូវឲ្យមានការឆ្លើយតបជាពហុវិស័យ។ វាមានសារៈសំខាន់ក្នុងការពិនិត្យឡើងវិញនូវច្បាប់បច្ចុប្បន្នស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ ដើម្បីធ្វើឲ្យប្រាកដថា ការឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា គឺស្របតាមបទដ្ឋានអន្តរជាតិ។ ស្ត្រីដែលបានរងគ្រោះដោយអំពើហិង្សាដោយសារបញ្ហាយេនឌ័រ និងផ្លូវភេទជួបប្រទះឧបសគ្គ នៅពេលដែលជនល្មើសគួរតែត្រូវបាននាំខ្លួនយ៉ាងឆាប់រហ័សទៅតុលាការដើម្បីផ្តន្ទាទោសទៅតាមច្បាប់។ ដោយសារតែកង្វះខាតជាទូទៅនៃវេទយិតភាពយេនឌ័រនៃការអនុវត្តច្បាប់ និងបុគ្គលិកតុលាការសម្រាប់ដោះស្រាយជាមួយនឹងជនរងគ្រោះដោយបទល្មើសរំលោភបំពានផ្លូវភេទ និងវប្បធម៌ស្ងៀមស្ងាត់ត្រូវបានគេប្រើប្រាស់ ដែលនាំអោយមានករណីមួយចំនួនប៉ុណ្ណោះអាចទៅដល់តុលាការ។ ការពង្រឹងយន្តការតុលាការដែលការពារសិទ្ធិជនរងគ្រោះ និងធានាឲ្យមានការផ្តន្ទាទោសត្រឹមត្រូវចំពោះជនល្មើស ព្រមទាំងការរៀបចំឲ្យមានវគ្គបណ្តុះបណ្តាលអំពីវេទយិតភាពយេនឌ័រក្នុងចំណោមមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ គឺជាជំហានដ៏សំខាន់ឈានទៅដោះស្រាយករណីទាំងនេះ។ នៅក្នុងករណីជាច្រើន ករណីនៃអំពើហិង្សាលើស្ត្រី រួមទាំងការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ត្រូវបាន "ដោះស្រាយ" ក្រៅប្រព័ន្ធតុលាការនៅថ្នាក់មូលដ្ឋាន។

ក្នុងអំឡុងពេលបំពេញបេសកកម្មរបស់ខ្ញុំ ខ្ញុំបានកត់សម្គាល់ពីនិន្នាការគួរឲ្យភ័យខ្លាចកាន់តែខ្លាំងឡើង នៅក្នុងប្រពៃណីនិងប្រព័ន្ធផ្សព្វផ្សាយសង្គមដែលអំពើហិង្សាលើស្ត្រីត្រូវបានគេរាយការណ៍ ថាមិនមានការគោរពចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្ស ឬសិទ្ធិជនរងគ្រោះឡើយ។ ភាពងាយរងគ្រោះទីពីរ តាមរយៈការខកខានក្នុងការការពារអត្តសញ្ញាណជនរងគ្រោះ រួមទាំងអនីតិជនបានបន្តកើតមានជារៀងរាល់ថ្ងៃតាមស្ថានភាពបែបនេះ។ ការមិនបំពេញតាមស្តង់ដាសីលធម៌វិជ្ជាជីវៈជាមូលដ្ឋាន នៅពេលធ្វើរបាយការណ៍ស្តីពីអំពើហិង្សាលើយេនឌ័រ និងការប្រើប្រាស់រូបភាពកេងប្រវ័ញ្ច និងបន្ទោកបន្ទាប បង្កើតឲ្យមានផ្នត់គំនិតរើសអើង និងរួមចំណែកដល់ការប្រកាន់ពូជសាសន៍ និងការធ្វើឲ្យអំពើហិង្សាលើស្ត្រីទៅជារឿងធម្មតា។ ខ្ញុំបានប្រាប់សមាជិកអ្នកសារព័ត៌មានថានៅពេលផ្តិតយកព័ត៌មានទាក់ទងនឹងករណីបែបនេះ សូមឲ្យគិតគូរប្រយ័ត្នប្រយែងអំពីសិទ្ធិរបស់ជនរងគ្រោះ។

ក្នុងអំឡុងពេលបំពេញទស្សនកិច្ចរបស់ខ្ញុំ ខ្ញុំបានយកឱកាសនេះជួបស្ត្រីមួយចំនួន ដែលធ្វើការនៅវិស័យឧស្សាហកម្មកាត់ដេរ។ ទន្ទឹមនឹងពួកគេទទួលបានផលប្រយោជន៍ពីរបបការពារយ៉ាងសំខាន់ និងឱកាសការចរចាជាសមូហភាព ប្រៀបធៀបជាមួយវិស័យការងារផ្សេងទៀត។ ទោះជាដូច្នេះក្តី ខ្ញុំមានការតក់ស្លុតយ៉ាងខ្លាំងពេលឃើញការលំបាករបស់ពួកគេក្នុងជីវភាពរស់នៅ និងលក្ខខណ្ឌការងារ។ ស្ថានភាពនេះ រិតតែអាក្រក់ថែមទៀតសម្រាប់កម្មករវិស័យផ្សេងទៀត ជាពិសេសកម្មករបំរើការនៅតាមផ្ទះ ដែលមិនមានការការពារផ្លូវច្បាប់ និងអាចត្រូវបានគេរំលោភបំពាននៅកន្លែងធ្វើការ និងឬស្ថានភាពការងារដោយបង្ខំ។ ត្រូវការឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីផ្តល់នូវការការពារទូលំទូលាយដល់កម្មករទាំងអស់ដោយច្បាប់ និងនៅក្នុងការអនុវត្តជាក់ស្តែង។

ពលករចំណាកស្រុកជាស្ត្រី ងាយនឹងរងគ្រោះក្នុងការក្លាយជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដូចដែលរបាយការណ៍ជាច្រើនបានបង្ហាញពីចំនួនកើនឡើងនៃករណីជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។ ខ្ញុំបានកត់សម្គាល់ដោយការពេញចិត្តអំពីគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហានេះ ជាពិសេសការបង្កើតគណៈកម្មាធិការពិសេសមួយនៅក្នុងក្រសួងមហាផ្ទៃ ដើម្បីដោះស្រាយបញ្ហាការជួញដូរមនុស្ស។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំនៅតែមានកង្វល់ថា ស្ត្រីពលករចំណាកស្រុក មិនទាន់ទទួលបាននូវការការពារយ៉ាងពេញលេញដោយច្បាប់នៅឡើយ។

លើសពីនេះទៀត វាបានបង្ហាញច្បាស់លាស់ណាស់តាមរយៈកិច្ចប្រជុំជាច្រើន ដែលបង្ហាញថា ស្ត្រីមិនមានភាពជាតំណាងស្មើគ្នានៅក្នុងជីវភាពនយោបាយ ដោយសារតែហេតុនេះហើយទើបមានឥទ្ធិពលតិចតួចក្នុងការធ្វើការសម្រេចនៅថ្នាក់ខ្ពស់។ អនុលោមតាមកាតព្វកិច្ចសន្ធិសញ្ញា កម្ពុជាបានទទួលយកដោយស្ម័គ្រចិត្ត ស្ត្រី និងបុរស គួរទទួលបានការចូលរួមដោយស្មើភាពគ្នា។ ខណៈពេលដែលប្រទេសកម្ពុជាត្រៀមរៀបការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងឆ្នាំ២០១៧ និងការបោះឆ្នោតជាតិ ក្នុងឆ្នាំ២០១៨ មានកិច្ចការជាច្រើនទៀត ដែលត្រូវធ្វើក្នុងការលុបបំបាត់ឧបសគ្គសម្រាប់ស្ត្រីក្នុងការឈរឈ្មោះបោះឆ្នោត និងមានឱកាសស្មើភាពគ្នាក្នុងការឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យ។ ខ្ញុំនឹងលើកយកបញ្ហាបញ្ជីឈ្មោះអ្នកបោះឆ្នោត ទៅពិភាក្សាជាមួយគណបក្សនយោបាយធំៗនានា។

**២. <u>សិទ្ធិជនជាតិដើមភាគតិច</u>**

ការខិតខំព្យាយាម ដែលបាននិងកំពុងធ្វើដើម្បីការពារនិងអភិរក្សវប្បធម៌ប្រពៃណីរបស់ ជនជាតិដើមភាគតិច ត្រូវបានជម្រុញលើកទឹកចិត្ត។ ខ្ញុំ,បានដឹងអំពីគម្រោងដែលផ្តោតលើភាសានិយាយរបស់

ជនជាតិដើមភាគតិច និងការអនុវត្តន៍វប្បធម៌ប្រពៃណី នៅពេលដែលខ្ញុំបានជួបប្រជុំជាមួយរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអំពីកម្មវិធីអប់រំពីរភាសា ពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងមួយចំនួន បានគូសបញ្ជាក់ពីបញ្ហាប្រឈមក្នុងការការពារសិទ្ធិជនជាតិដើមភាគតិចអោយស្របតាមបទដ្ឋានអន្តរជាតិ ស្របគ្នានិងការបន្តអភិវឌ្ឍប្រទេសផងនោះ។ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ បានប្តេជ្ញាចិត្តអនុវត្តវិធីសាស្ត្រទូលំទូលាយ ចំពោះជនជាតិដើមភាគតិច ការតាំងទីលំនៅថ្មីរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មិនមែនជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ធំៗ។ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចែករំលែកគំរោងរបស់ក្រសួង ដើម្បីចេញប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិចចំនួនហាសិបសហគមន៍ ក្នុងឆ្នាំ ២០១៨។

ក្នុងបេសកកម្មនេះ ខ្ញុំបានធ្វើដំណើរទស្សនកិច្ចទៅកាន់ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ ដែលបានទៅទស្សនាសហគមន៍ទាំងឡាយ ដែលរងផលប៉ះពាល់ដោយការតាំងទីលំនៅថ្មីជាក់ស្តែង ឬដែលមានក្នុងគម្រោងផងដែរ ជាមួយគ្នានេះខ្ញុំបានជួបពិភាក្សាជាមួយអភិបាលខេត្តនិងតំណាងក្រុមហ៊ុនដែលពាក់ព័ន្ធ។ វាច្បាស់ណាស់ថាទោះបីជាកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងនានាក្តី ក៏នៅមានជម្លោះដីធ្លីជាច្រើនមិនទាន់បានដោះស្រាយ។ ដូចជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលខេត្តស្ទឹងត្រែងហាក់ដូចជាដឹងច្បាស់ពីបញ្ហានេះនៅក្នុងការគោរពសិទ្ធិជនជាតិដើមភាគតិចដែលជាការធានាដោយច្បាប់កម្ពុជា និងអន្តរជាតិ ខណៈដែលទទួលស្គាល់សិទ្ធិផ្តាច់មុខនៃកម្ពុជាក្នុងការអភិវឌ្ឍនេះ។

ការសម្របសិទ្ធិជនជាតិដើមភាគតិច ចំពោះរបៀបរបបរស់នៅតាមប្រពៃណី ទៅនឹងការអប់រំ សុខភាពនិងហេដ្ឋារចនាសម្ព័ន្ធដទៃទៀតបែបទំនើប បង្កើនការប្រឈមនូវភាពលាយឡំគ្នាពាក់ព័ន្ធនឹងការការពារ។ ខ្ញុំគិតថា វាជាសញ្ញាមួយនៃវឌ្ឍនភាពដែលមន្ត្រីរដ្ឋាភិបាលដែលខ្ញុំបានជួបបានទទួលស្គាល់ថា មានកង្វះខាតការធានាការការពារគ្រប់គ្រាន់រយៈពេលកន្លងមក បាននាំឱ្យមានបញ្ហារហូតដល់បច្ចុប្បន្ននេះ ហើយពួកគេបានបញ្ឈប់គោលនយោបាយដែលមានបញ្ហានេះ ដូចជាការផ្តល់ដីសម្បទានសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំបានជម្រុញឱ្យបង្កើតយន្តការបណ្តឹងពាក់ព័ន្ធនឹងសិទ្ធិមនុស្សដើម្បីដោះស្រាយបញ្ហានេះនៅថ្ងៃអនាគត។ យន្តការមួយនេះគួរតែធានាឲ្យមានការពិគ្រោះយោបល់ឱ្យបានហ្មត់ចត់ពិតប្រាកដ ជាមួយសហគមន៍ទាំងឡាយដែលរងផលប៉ះពាល់។ បង្កើនកិច្ចខិតខំប្រឹងប្រែងថែមទៀត និងទុកពេលច្រើនបន្ថែមទៀត ក្នុងដំណើរការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច ដើម្បីធ្វើឲ្យប្រាកដថាពិតជាមានការចូលរួមពេញលេញពីប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ការ

គោរពវប្បធម៌ និងប្រពៃណី និងការព្រមព្រៀងដោយសេរី និងដោយទទួលបានព័ត៌មានគ្រប់គ្រាន់ ជាមុន។

កាលបើគ្មានជម្រើសណាមួយ ក្រៅពីការតាំងលំនៅថ្មីនោះ អ្នកស្រុកត្រូវតែបានគេជូនដំណឹងគ្រប់គ្រាន់និងទទួលបានសំណងសមរម្យ និង/ឬ លំនៅដ្ឋានជំនួសសមរម្យ ព្រមទាំងផ្តល់ឲ្យពួកគាត់នូវការឧបត្ថម្ភគាំទ្រនៅក្នុងអំឡុងពេលអន្តរកាលនេះ។ ផែនការច្បាស់លាស់និងមានតម្លាភាពអំពីការតាំងលំនៅថ្មី គួរតែមានការឯកភាពយល់ព្រមជាមុនសិន មុននឹងផ្លាស់សហគមន៍នោះទៅនៅទីតាំងថ្មី។ ក្នុងករណីមានការផ្លាស់ទីលំនៅថ្មីរបស់សហគមន៍ជនជាតិដើមភាគតិច ផែនការផ្លាស់ទីលំនៅថ្មី គួរតែចាត់ចែងផងដែរ អំពីការអភិរក្សព្រៃអារក្ស ដីកប់ខ្មោច និងការអនុវត្តសិទ្ធិអាស្រ័យផល។ ប្រការដែលគួរឲ្យចាប់អារម្មណ៍នោះគឺ ខ្ញុំបានជួបប្រជុំជាមួយអ្នកតំណាងក្រុមហ៊ុនមួយចំនួន ពួកគេនិយាយពីការ ខកចិត្តដោយខ្លួនបានជាប់ពាក់ព័ន្ធក្នុងទំនាស់ដីធ្លី បើទោះជាខ្លួនបានអនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់ហើយក្តី។ ដល់ពេលវេលាសម្រាប់កម្ពុជា អនុម័តវិធីសាស្ត្របង្ការសម្រាប់ការគ្រប់គ្រងដីធ្លី និងការដោះស្រាយរាល់ការកើតទុក្ខមិនសុខចិត្តទាក់ទងនឹងបញ្ហានេះ។

ដោយសារមានទំនាស់ដីធ្លីរ៉ាំរ៉ៃជាច្រើន និងការរីកសាយភាយនៃទំនាស់ថ្មីច្រើនទៀតនោះ ខ្ញុំស្វាគមន៍កិច្ចខិតខំប្រឹងប្រែងក្នុងបង្កើនយន្តការបណ្តឹង ដើម្បីឲ្យយន្តការនេះអាចអនុវត្តមានប្រសិទ្ធភាពពិតប្រាកដ។

### *៣) ការអប់រំសិទ្ធិមនុស្ស និងសិទ្ធិទទួលបានការសិក្សា*

សម្រាប់រូបខ្ញុំផ្ទាល់ ការដោះស្រាយបញ្ហាសិទ្ធិមនុស្សទាំងនេះត្រូវមាននូវការប្រាស្រ័យទាក់ទងកាន់តែទូលំទូលាយឡើង និងមានការពង្រឹងការអប់រំក្នុងន័យទូលំទូលាយបំផុត។ ការកើនឡើងនៃការប្រើប្រាស់ភាសាសិទ្ធិមនុស្ស ស្តែងឲ្យឃើញនូវភាពរីកចម្រើននៃការយល់ដឹងអំពីសិទ្ធិមនុស្សនៅកម្ពុជា។ ខ្ញុំដឹងអំពីការវិវត្តន៍រីកចម្រើនលើសមភាពនៃការអប់រំ និងអក្ខរកម្ម ជាពិសេស ក្នុងចំណោមកុមារតូចៗ និងភាពល្អប្រសើរឡើងនូវសិទ្ធិទទួលបានសេវាសុខភាពសម្រាប់ស្ត្រី និងកុមារី។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អ.ស.បនឹងធានាឲ្យមានការផ្តោតការយកចិត្តទុកដាក់លើបញ្ហាទាំងនេះសម្រាប់ប៉ុន្មានឆ្នាំខាងមុខនេះ។

បញ្ហាប្រឈមចំពោះមុខនាពេលនេះគឺត្រូវផ្គូផ្គងការរីកចម្រើននៃការគ្រប់គ្រងលើការអប់រំជាមួយនឹងមាតិកាដែលបានកែទម្រង់។ វាតម្រូវឲ្យមានសិទ្ធិមនុស្សដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមសាលា ដើម្បីចូលរួមចំណែកឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀតដល់ការយល់ដឹង និងការទទួលយកនូវសិទ្ធិមនុស្ស ដែលកម្ពុជាបានទទួលយកមកអនុវត្តរួចមកហើយនោះ។ ខ្ញុំបានទទួលយកនូវសំណើរ ដែល

ផ្តល់មកឲ្យរូបខ្ញុំដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងការជួយពិនិត្យឡើងវិញនូវ កម្មវិធីសិក្សា ដើម្បីធានាឲ្យមានការដាក់បញ្ចូលនូវធាតុនានានៃការអប់រំសិទ្ធិមនុស្ស។

**៤) ស្ថានភាពទូទៅ**

ខ្ញុំបានចង្អុលបង្ហាញតាំងពីដំបូងនូវការព្រួយបារម្ភរបស់ខ្ញុំដែលថាប្រទេសកម្ពុជាគឺកំពុងខិតទៅជិតចំនុចកំពូលនៃគ្រោះថ្នាក់ហើយ។ មេដឹកនាំដែលចេញពីការបោះឆ្នោតទាំងអស់ មានទំនួលខុសត្រូវក្នុង ការធ្វើសកម្មភាពដើម្បីជាប្រយោជន៍ដល់អ្នកដែលពួកគេតំណាងឲ្យ។ ទន្ទឹមនឹងមានអំណាច ក៏មាននូវ ការទទួលខុសត្រូវក្នុងការគោរពសេចក្តីថ្លៃថ្នូរ និងសិទ្ធិមនុស្សទាំងអស់ មិនមែនគ្រាន់តែសិទ្ធិមាន ជិវិតឯកជននោះទេ។ ច្បាប់ទាំងអស់ត្រូវតែបានអនុវត្តដោយស្មើភាពគ្នា និងដោយយុត្តិធម៌ ដល់គ្រប់ គណបក្សនយោបាយ និងសមាជិករបស់គណៈបក្សទាំងនោះ ដើម្បីធានាឲ្យមាននូវកិច្ចការពារលំហ ប្រជាធិបតេយ្យ នៅក្នុងដំណើរការបោះឆ្នោត។ ស្ថានការណ៍នយោបាយដែលរាប់ទាំង ការគំរាមកំហែង ជាថ្មី កិច្ចដំណើរការនីតិវិធីរបស់តុលាការ និងសូម្បីតែការវាយដំលើរាងកាយរបស់សមាជិក គណបក្សប្រឆាំង គឺសុទ្ធតែជាការគួរព្រួយបារម្ភ។

***សេរីភាពសម្តែងមតិ ការបង្កើតសមាគម និងការជួបប្រជុំដោយសន្តិវិធី***

ត្រូវមានការយកចិត្តទុកដាក់ដើម្បីធានាថា ការរិតត្បិតណាមួយលើសេរីភាពសម្តែងមតិ ការជួបប្រជុំនិងបង្កើតសមាគម គឺអនុលោមតាមច្បាប់ និងជាការពិតណាស់ គឺអនុលោមតាមបទដ្ឋាន សិទ្ធិមនុស្សអន្តរជាតិ។ ការបង្កើតច្បាប់ រាប់ទាំងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសសមាជិកសភា ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីទូរគមនាគមន៍ និងសេចក្តីព្រាងច្បាប់ ស្តីពីសហជីព (ដែលខ្ញុំយល់ថានឹងត្រូវអនុម័តដោយរដ្ឋសភាជាតិនៅដើមខែក្រោយ) គឺធ្វើឲ្យមានការ ព្រួយបារម្ភណាស់។ ភាគីពាក់ព័ន្ធជាច្រើនបានគូសបញ្ជាក់ពីនយោបាយកម្មដែលបានអះអាងក្នុងការ អនុវត្តនូវច្បាប់ទាំងនេះ និងច្បាប់ដទៃទៀតរបស់ព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំសង្ឃឹមថា ដូចគ្នានឹង ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីដែរ រដ្ឋាភិបាលនឹងបង្កើតមគ្គុទេសក៍សម្រាប់ការអនុវត្តន៍លើច្បាប់ ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល(LANGO) ដោយត្រូវបញ្ជាក់អំពីការអនុវត្តច្បាប់នេះឲ្យស្រប នឹងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលនឹងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ជាពិសេស ដល់អ្នក ដែលចូលរួមនៅក្នុងការអនុវត្តច្បាប់ និងរដ្ឋបាលយុត្តិធម៌។ បញ្ហានានាកើតឡើង នៅពេលដែលច្បាប់មិន ត្រូវបានអនុវត្តដោយសង្កតភាពចំពោះមនុស្សគ្រប់រូប។ ការណ៍នេះនាំឲ្យមានភាពតានតឹង និងពាក្យ បណ្តឹងដែលមិនគួរកើតមាន។ ឧទាហរណ៍ មន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរខេត្តទាំងអស់ ចាំបាច់ត្រូវ មានការយល់ដឹងអំពីសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដែលមិនត្រឹមតែផ្នែក ៣-២ នោះទេដែលមិនតម្រូវឲ្យមានការអនុញ្ញាតជាមុនសម្រាប់សកម្មភាព អប់រំ និងកិច្ចប្រជុំនានាដើម្បីពិភាក្សា និងស្វែងរកដំណោះស្រាយសម្រាប់បញ្ហាណាមួយ។ វិធីនេះមិន ត្រូវបានកំពុងអនុវត្តដោយ

សង្គតភាពឡើយ ដោយឃើញថាសកម្មភាពអប់រំជាទូទៅ និងកិច្ចប្រជុំនានា របស់សហគមន៍ ជាពិសេស ទាក់ទងនឹងបញ្ហាដីធ្លី ដែលបញ្ហាទាំងអស់នោះ ជាញឹកញយណាស់ត្រូវ បានរឹតត្បិត។ ការទប់ស្កាត់សកម្មភាពតាមអំពើចិត្តដោយអាជ្ញាធរអនុវត្តច្បាប់ តម្រូវឲ្យមានកម្មវិធី បណ្តុះបណ្តាលត្រឹមត្រូវសម្រាប់អាជ្ញាធរដែលជាមន្ត្រីអនុវត្តច្បាប់ទាំងនោះស្តីពីច្បាប់នានាដែលពួកគេត្រូវពង្រឹងការអនុវត្ត។

ខ្ញុំបានជួបប្រទះដោយខ្លួនឯងផ្ទាល់នូវអ្វីដែលអង្គការមិនមែនរដ្ឋាភិបាលកំពុងប្រឈម នៅពេលដែលមន្ត្រីនគរបាលឃុំ (មិនមានស្លៀកពាក់ឯកសណ្ឋាន) បានព្យាយាមដើម្បីបញ្ឈប់ការជួបប្រជុំរបស់ខ្ញុំជាមួយនឹងជនជាតិដើមភាគតិចគួយនៅខេត្តព្រះវិហារ។ គោលការណ៍ណែនាំអនុវត្តអំពីច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ចែងយ៉ាងច្បាស់ថា កិច្ចប្រជុំបែបនេះមិនតម្រូវឲ្យមានការជូនដំណឹង ឬការអនុញ្ញាតនោះទេ។

## *ដំណើរការនីតិកម្ម*

ពាក់ព័ន្ធនឹងនីតិកម្មវិញ ខ្ញុំបានលើកឡើងជាថ្មីម្តងទៀតជាមួយសមាជិកសភានូវបំណងប្រាថ្នាក្នុងការបោះពុម្ពផ្សាយ និងផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវសេចក្តីព្រាងច្បាប់ ដើម្បីសម្រួលឲ្យមាន កិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យលើអត្ថបទច្បាប់ទាំងនោះមុននឹងការអនុម័ត។ ការចូលរួម ពិភាក្សាប្រកបដោយអត្ថន័យក្នុងអំឡុងការពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់ អាចជួយសម្រាលនូវ កង្វល់ និងលទ្ធផលផ្លាស់ប្តូរជាវិជ្ជមានអំពីច្បាប់នានាដែលអាចនឹងកើតមានបញ្ហា។ សេចក្តីព្រាងច្បាប់ សហជីពបានចាប់ផ្តើមដំណើរការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ហើយច្បាប់ស្តីពីសិទ្ធិទទួលបាន ព័ត៌មានត្រូវបានពិចារណាដោយដំណើរការយ៉ាងទូលំទូលាយ ដោយធាតុចូលបានមកពីតួអង្គជាច្រើន។ ប្រធានស្តីទីរដ្ឋសភា បានធានាចំពោះមុខខ្ញុំថា សេចក្តីព្រាងច្បាប់ទាំងអស់ត្រូវបានដាក់នៅលើគេហទំព័រ របស់រដ្ឋសភា បន្ទាប់ពីទទួលបានពីទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាជំហ៊ានដំបូងដ៏សំខាន់ និងទទួលបាន ការស្វាគមន៍។ ក្នុងគ្រប់ករណីទាំងអស់ ច្បាប់ដែលចូលជាធរមានហើយ ត្រូវតែអនុវត្តដោយស្មើភាព ចំពោះជនគ្រប់រូប។ វាគឺជាប្រការសំខាន់ដែលត្រូវមានវិធាននានារួចជាស្រេចដើម្បីធានាឲ្យមានតម្លាភាព ក្នុងការធ្វើច្បាប់។

## *ប្រព័ន្ធតុលាការ*

ខ្ញុំដឹងថាការងារដែលចាំបាច់ត្រូវធ្វើឲ្យបានចប់សព្វគ្រប់ក្នុងការពង្រឹងឯករាជ្យភាព របស់ប្រព័ន្ធតុលាការ និងធានាឲ្យមានដំណើរការនៃប្រព័ន្ធតុលាការដោយយុត្តិធម៌សម្រាប់ជនគ្រប់រូប និងការទទួលបានសំណងសមរម្យ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏បានយល់ផងដែរ ហើយនៅតែចូលរួមក្នុងដំណើរការ នៃកំណែទម្រង់។ មានកិច្ចអភិវឌ្ឍមួយចំនួនដែលគួរឲ្យស្វាគមន៍ ចាប់តាំងពីដំណើរទស្សនកិច្ចចុងក្រោយ

របស់ខ្ញុំ មិនត្រឹមតែការឡើងប្រាក់បៀវត្សរ៍របស់មន្ត្រីតុលាការ ដើម្បីធានាឲ្យចៅក្រមមានកម្រិត ជីវភាពសមរម្យ កិច្ចខិតខំប្រឹងប្រែងរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងការផ្សព្វផ្សាយ ក្រមសីលធម៌តុលាការ ឆ្នាំ២០០៧ ការពង្រីក មូលដ្ឋានទិន្នន័យសម្រាប់ការផ្ទុកឲ្យកាន់តែល្អប្រសើរជាងមុន និងការ ប្រើប្រាស់ព័ត៌មានអំពីរឿងក្តីនៅតុលាការ និងបង្កើនការទំនាក់ទំនងក្នុងចំណោមតួអង្គតុលាការ ដែលអាចជួយធ្វើឲ្យមានចំណាត់ការលឿនជាងមុន និងសម្រេចបានកាន់តែមានសង្គតភាពជាងមុនលើប្រភេទរឿងក្តីជាក់លាក់នានា។ ខ្ញុំទន្ទឹងរង់ចាំនូវការផ្លាស់ប្តូរជាវិជ្ជមានបន្ថែមទៀតនៅក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ។

មានកិច្ចការច្រើនទៀតដែលត្រូវធ្វើដើម្បីបង្ហាញជាសាធារណៈថា ក្រសួងយុត្តិធម៌កំពុងដើរតួនាទីគាំទ្ររដ្ឋបាលសុទ្ធសាធពាក់ព័ន្ធនឹងតុលាការ។ កិច្ចការត្រូវបន្តធ្វើគឺ ត្រូវពង្រឹងទាំងឯករាជ្យភាពពិតប្រាកដរបស់ស្ថាប័នតុលាការ និងការធ្វើឲ្យតុលាការមានការបែងចែកដាច់ពីស្ថាប័នផ្សេងៗទៀតរបស់រដ្ឋាភិបាល។ ការធ្វើការសម្រេចរបស់តុលាការ និងសាលក្រមស្ថាពរ គួរតែសាធារណៈជនអាចចូលបាន ដោយមានទិន្នន័យគ្រប់គ្រាន់បន្ថែមទៀត ព្រមទាំងបង្កើនការបណ្តុះបណ្តាលឲ្យបានច្រើនដល់មន្ត្រីតុលាការ។ ជាចុងក្រោយ ការពិនិត្យឡើងវិញលើទម្រង់នៃការប្រើប្រាស់ដ៏រីករាលដាលនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលខុសពីការត្រួតពិនិត្យតាមផ្លូវតុលាការ អាចនឹងកាត់បន្ថយបាននូវភាពចង្អៀតណែននៃអ្នកទោសនៅ ក្នុងពន្ធនាគារ និងពង្រឹងការគោរពសិទ្ធិរបស់ជនជាប់ឃុំ។

## *ការត្រៀមរៀបចំការបោះឆ្នោត*

ខ្ញុំបានឆ្លៀតឱកាសជួបពិភាក្សាការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយសារតែការងាររបស់គណៈកម្មាធិការនេះផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការបោះឆ្នោត នៅឆ្នាំ២០១៧-២០១៨។ វាជាប្រការសំខាន់ដែលត្រូវគិតគូរពិចារណាពីឱកាសចុះឈ្មោះដែលអាចទទួលយកបាន និងអាចចូលទៅមើលបាន សម្រាប់ប្រជាជនកម្ពុជាទាំងអស់ដែលអាចបោះឆ្នោតបាន មិនត្រឹមតែ ពលករទេសន្តរប្រវេសន៍ (នៅក្នុងប្រទេសកម្ពុជា និងនៅក្រៅប្រទេស) ព្រមទាំងអ្នកជាប់ឃុំផងដែរ។ កាន់តែសំខាន់ជាងនេះទៅទៀតនោះគឺ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (NEC) អាចធ្វើការ ដោយឯករាជ្យដើម្បីធានាថាការបោះឆ្នោតអាចឲ្យទុកចិត្តបាន។ នេះតម្រូវឲ្យមានការចុះបញ្ជីឲ្យបានទាន់ ពេលវេលាសម្រាប់អ្នកមានសិទ្ធិបោះឆ្នោតទាំងអស់ លុះណាតែ មនុស្សគ្រប់គ្នាអាចបោះឆ្នោតបានតែម្តង និងមានប្រព័ន្ធរាប់សន្លឹកឆ្នោតសមរម្យ និងតម្លាភាព។ ខ្ញុំមានសេចក្តីរីករាយដែលបានដឹងថា គ.ជ.ប និងក្រសួងមហាផ្ទៃ កំពុងដំណើរការដោយមានការចេញអត្តសញ្ញាណប័ណ្ណជីវមាត្រដល់អ្នកមានសិទ្ធិ បោះឆ្នោតទាំងអស់ បើទោះបីជាបញ្ហាប្រឈមនៅតែមានក៏ដោយ។

*<u>សន្និដ្ឋានបញ្ចប់</u>*

ក្នុងអំឡុងពេលបេសកកម្មរបស់ខ្ញុំ ខ្ញុំបានទទួលប្រយោជន៍ពីព័ត៌មាន និងការយល់ដឹងដែលបានចែករំលែកដោយសប្បុរសជាមួយខ្ញុំ ដោយតួអង្គជាច្រើន មានតួអង្គជាតិ និងអន្តរជាតិ រដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល។ ដូចកាលពីទស្សនកិច្ចលើកមុនដែរ ខ្ញុំសូមថ្លែងអំណរគុណចំពោះការគាំទ្រដល់រូបខ្ញុំពីសំណាក់អ្នកជំនាញការរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំកម្ពុជា។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់អង្គការសហប្រជាជាតិសម្រាប់សមភាពយេនឌ័រ និង ពង្រឹងអំណាចស្ត្រី (UN Women) ចំពោះការគាំទ្ររបស់ខ្លួន។ កាលពីម្សិលមិញ ខ្ញុំមានកិត្តិយសដែលបានធ្វើសេចក្តីសង្ខេបជូនសម្តេចក្រឡាហោម ស ខេង អំពីការរកឃើញបឋម របស់ខ្ញុំ។

អនុសាសន៍ពេញលេញរបស់ខ្ញុំទៅរាជរដ្ឋាភិបាលកម្ពុជានឹងត្រូវបានគូសបញ្ជាក់នៅក្នុងរបាយការណ៍នាពេលខាងមុខរបស់ខ្ញុំទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នេះបើយោងតាមកាលវិភាគនៅពេលបច្ចុប្បន្ន នេះ របាយការណ៍នេះនឹងអាចរកបាននៅក្នុងខែសីហា មុនសម័យប្រជុំលើកទី៣៣ នៃក្រុមប្រឹក្សាសិទ្ធិ មនុស្ស អ. ស.ហ នៅខែកញ្ញា ឆ្នាំ២០១៦។

ចប់

*លោកស្រី សាស្ត្រាចារ្យ រ៉ូណា ស្មីត (ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងក្នុងខែមីនា ឆ្នាំ២០១៥។ អាណត្តិរបស់អ្នករាយការណ៍ពិសេស កើតចេញពីកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស ស្តីពីដំណោះស្រាយនយោបាយទូលំទូលាយនៃជម្លោះកម្ពុជា។ លោកស្រី ស្មីត គឺជាសាស្ត្រាចារ្យនីតិសិទ្ធិមនុស្សអន្តរជាតិ នៅចក្រភពអង់គ្លេស ហើយនៅពេលកន្លងមក លោកស្រី បានបង្រៀនច្បាប់សិទ្ធិមនុស្ស និងបានអនុវត្តសកម្មភាពកសាងសមត្ថភាពសិទ្ធិមនុស្សនៅកម្ពុជា។*

អ្នករាយការណ៍ពិសេសគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ដែលជាស្ថាប័នធំបំផុតមួយរបស់អ្នកជំនាញការឯករាជ្យ នៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស .ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឯករាជ្យ ឃ្លាំមើលនិងស្វែងរកការពិត របស់ក្រុមប្រឹក្សា សិទ្ធិមនុស្ស ដែលដោះស្រាយទាំងស្ថានភាពជាក់លាក់នៃប្រទេសនីមួយៗ ទាំងបញ្ហាតាមវិស័យមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ អ្នកជំនាញការនៃនីតិវិធីពិសេស ធ្វើការផ្អែកលើគោលការណ៍ ស្ម័គ្រចិត្ត គាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍ពីការងាររបស់គាត់ដែរ។ គាត់ធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលគាត់ផ្ទាល់។

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា*
http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx and http://cambodia.ohchr.org

សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗសូមទាក់ទងមក ៖

នៅរាជធានីភ្នំពេញ៖ កញ្ញា គ្រីសស្ទីន ភិឃើរីង (Ms. Christine Pickering) តាមរយៈទូរស័ព្ទលេខ (+៨៥៥ ២៣ ៩៩៣ ៥៩០/៩១ លេខភ្ជាប់បន្ត៖ ៣០៦ ឬ អ៊ីម៉ែល cpickering@ohchr.org)

នៅទីក្រុងបាងកក ៖ លោកជេរីមី ឡូរិន (Mr. Jeremy Laurence) *(+66 84 700 4671 / laurencej@un.org)*

នៅទីក្រុងហ្សឺណែវ៖ សម្រាប់ការសាកសួរព័ត៌មានអំពីអ្នកជំនាញការឯករាជ្យដទៃទៀត របស់ អ.ស.ប សូមទាក់ទង៖

សាប៊ៀរ សែលាយ៉ា (Xabier Celaya) អង្គភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉ែល xcelaya@ohchr.org)

សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមបណ្តាញព័ត៌មានសង្គម ៖

ហ្វេសប៊ុក៖ https://www.facebook.com/unitednationshumanrights និង
https://www.facebook.com/OHCHRCambodia
ទ្វីតធឺ៖ http://twitter.com/UNrightswire and http://twitter.com/OHCHR_Cambodia
ហ្គោហ្គើល Google+ gplus.to/unitednationshumanrights
យូធូប៖ http://www.youtube.com/UNOHCHR

ផែនលិបិក្រមសិទ្ធិមនុស្សជាសកល ៖ http://uhri.ohchr.org/en